**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**តុលាការរដ្ឋប្បវេណី**

# សាលក្រម

រឿងក្តីលេខ ៨៣ ប.អ.ស ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣
សញ្ញាណនៃរឿងក្តី ៖ ទាមទារដី
ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ៖ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣
សាលក្រមលេខ **៤៣ "ឈ"/ ២៩៨**
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

**ចៅក្រម**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តសៀមរាប

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប

ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ

**ដើមចោទ**

ឈ្មោះ [redacted] **សុះឿន** ភេទស្រី សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 050837128 អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted]

ដោយមានលោកមេធាវី [redacted] អត្តលេខ ២៧៦ និងលោកមេធាវី [redacted] អត្តលេខ ២៦៥៣T មេធាវីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីនៃ **ការិយាល័យមេធាវី** [redacted] តាំងនៅអាគារលេខ [redacted] ជា **មេធាវីតំណាងដោយអាណត្តិ** ។

**ចុងចម្លើយ**

ឈ្មោះ [redacted] **កែវមុនី** ភេទស្រី អាយុ៥៩ឆ្នាំ កើតឆ្នាំ១៩៦៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010407104 ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២ អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ [redacted] ។

### អង្គហេតុ និងចំណុចវិវាទ

**១- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១-១ បញ្ជាក់ថា ដើមចោទជាអ្នកមានអត្តិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ **៤៧.៦០៦ម$^{២}$** មានក្បាល



Scanned with CamScanner

ដីលេខ I$_{II}$ 0014 មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

១-២ បង្គាប់ឱ្យចុងចម្លើយនីមួយៗ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរសិទ្ធិលើដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ I$_{II}$ 0014 មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ឱ្យដើមចោទឈ្មោះ [redacted] សុជឿន ។

១-៣ ឱ្យដើមចោទ ទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

## ២- ការពន្យល់គ្រួសៗនៃរឿងក្ដី

**២-១** ក្នុងរឿងក្ដីនេះ ចុងចម្លើយឈ្មោះ [redacted] **កែវមុនី** និងប្ដីឈ្មោះ [redacted] **គីវឡុន** មានដីមួយកន្លែងទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ I$_{II}$ 0014 មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ ក្រោយពីឈ្មោះ [redacted] **គីវឡុន** បានទទួលមរណភាព នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥ ទៅ ដីនេះក៏ស្ថិតនៅក្រោមការកាន់កាប់គ្រប់គ្រងរបស់ឈ្មោះ [redacted] **កែវមុនី** ។ លុះនៅចុងឆ្នាំ២០០៧ ឈ្មោះ [redacted] **កែវមុនី** ក៏បានលក់ដីខាងលើនេះឱ្យមកឈ្មោះ [redacted] **ជីតា** និងឈ្មោះ [redacted] **សារឹម** ដោយមានការព្រមព្រៀងពីកូនៗរបស់ភាគីអ្នកលក់ឈ្មោះ [redacted] **កែវមុនី** ផងដែរ ។ ក្នុងការអនុវត្តការលក់-ទិញនេះ ឈ្មោះ [redacted] **កែវមុនី** បានធ្វើលិខិតផ្ទេរដីដែលបានលក់-ទិញនេះ មកឱ្យឈ្មោះ [redacted] **ជីតា** និងឈ្មោះ [redacted] **សារឹម** តាមលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៧ ។ បន្ទាប់ពីបានធ្វើការផ្ទេរសិទ្ធិដីដែលបានលក់-ទិញ តាមលិខិតផ្ទេរសិទ្ធិខាងលើនេះហើយ ភាគីទាំងពីរមិនបានទៅធ្វើការចុះបញ្ជីផ្ទេរសិទ្ធិទៅតាមនីតិវិធីនៃដីដែលមានប័ណ្ណនោះទេ ព្រោះយល់ថា គ្រាន់តែធ្វើត្រឹមលិខិតផ្ទេរសិទ្ធិ វាជាការគ្រប់គ្រាន់ក្នុងការទិញលក់នេះហើយ ។ ឈ្មោះ [redacted] **ជីតា** បន្ទាប់ពីទទួលបានទិញដីខាងលើនេះមក ក៏បានលក់ដីនេះបន្តមកឱ្យដើមចោទឈ្មោះ [redacted] **សុជឿន** តាមកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ។ ក្នុងការលក់-ទិញនេះ ភាគីដើមចោទបានទូទាត់ប្រាក់ថ្លៃដីឱ្យភាគីអ្នកលក់ឈ្មោះ [redacted] **ជីតា** រួចរាល់អស់ហើយ ហើយនៅពេលដែលយកឯកសារមកធ្វើការចុះបញ្ជីផ្ទេរសិទ្ធិ ទើបដឹងថាដីដែលបានលក់-ទិញនេះ ថ្វីត្បិតតែមានការលក់-ទិញនិងបានផ្ទេរសិទ្ធិដូចបានបញ្ជាក់ខាងលើនេះក្ដី តែនីតិវិធីនៃការចុះបញ្ជីផ្ទេរសិទ្ធិឱ្យដើមចោទ (ជាអ្នកទិញចុងក្រោយ)ពេញលេញតាមលក្ខណៈផ្លូវច្បាប់នោះ គឺតម្រូវឱ្យម្ចាស់ដីដើមឈ្មោះ [redacted] **កែវមុនី** ធ្វើការបំពេញនីតិវិធីឱ្យបានត្រឹមត្រូវឡើងវិញ ។

**២-២ ចំណុចវិវាទ**

ក្នុងរឿងក្ដីនេះ មិនមានចំណុចវិវាទ ទេ ។

## ៣- ការអះអាងរបស់គូភាគី

### ៣-១ ការអះអាងរបស់ភាគីដើមចោទ

លោកមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថាខ្លួននៅតែរក្សាការទាមទាររបស់ខ្លួន ដូចក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ និងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការ



Scanned with CamScanner

ទាញហេតុផល ដដែល គឺបញ្ជាក់ថា ដើមចោទជាអ្នកមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **$I_{II}$ 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប និងបង្គាប់ឱ្យចុងចម្លើយ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរសិទ្ធិលើដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **$I_{II}$ 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ឱ្យមកដើមចោទ ដោយហេតុថា ដីដែលដើមចោទបានទិញពីឈ្មោះ [redacted] **ជីតា** តាមកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ខាងលើ គឺជាដីដែលឈ្មោះ [redacted] **ជីតា** មានសិទ្ធិពេញលេញក្នុងការលក់មកឱ្យដើមចោទ តែគ្រាន់តែនីតិវិធីនៃការចុះបញ្ជីផ្ទេរសិទ្ធិមកឱ្យដើមចោទ ឈ្មោះ [redacted] **ជីតា** មិនអាចធ្វើនីតិវិធីក្នុងការចុះបញ្ជីផ្ទេរសិទ្ធិដីនេះមកឱ្យដើមចោទបាន គឺតម្រូវឱ្យម្ចាស់ដើមជាចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ជាអ្នកមកបំពេញកាតព្វកិច្ចនេះ ។ ហេតុនេះ ដើម្បីធានាដល់សិទ្ធិស្របច្បាប់របស់ដើមចោទលើដីដែលបានទិញដោយស្របច្បាប់ និងដើម្បីឱ្យដើមចោទទទួលបានដីដែលបានទិញដោយស្របច្បាប់នេះពេញលេញ ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចបានប្តឹងសុំខាងលើ ដើម្បីអនុវត្តដោយបង្ខំ ។

**ក- អំពីការទាមទារឱ្យបញ្ជាក់អត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ ៤៧.៦០៦ម² មានក្បាលដីលេខ $I_{II}$ 0014**

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា ការទាមទារនេះដោយហេតុថា ដីខាងលើនេះ ចុងចម្លើយនិងឈ្មោះ [redacted] **ជីតា** បានលក់និងផ្ទេរសិទ្ធិមកឱ្យឈ្មោះ [redacted] **ជីតា** ដោយស្របច្បាប់ តែគ្រាន់តែមិនទាន់បានចុះបញ្ជីទៅតាមនីតិវិធីតែប៉ុណ្ណោះ ។ ចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ត្រូវបាត់សិទ្ធិ (នត្ថិភាពនៃសិទ្ធិ)ជាម្ចាស់កម្មសិទ្ធិលើដីនេះហើយ ។ ឈ្មោះ [redacted] **ជីតា** បានលក់ដីខាងលើនេះមកឱ្យដើមចោទ បន្តតាមកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ហើយក្នុងការអនុវត្តកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី)នេះ ដើមចោទបានអនុវត្តទូទាត់ប្រាក់ថ្លៃទិញរួចរាល់អស់ហើយ នៅឡើយតែភាគីអ្នកលក់ឈ្មោះ [redacted] **ជីតា** ត្រូវអនុវត្តកាតព្វកិច្ចក្នុងការចុះបញ្ជីផ្ទេរសិទ្ធិលើដីដែលបានលក់-ទិញមកឱ្យដើមចោទ តែតាមនីតិវិធីមិនអាចឱ្យឈ្មោះ [redacted] **ជីតា** ចុះបញ្ជីផ្ទេរសិទ្ធិបាន ព្រោះកាលដែលឈ្មោះ [redacted] **ជីតា** ទទួលសិទ្ធិពីម្ចាស់ដើមឈ្មោះ [redacted] **កែវមុនី** មកនោះ មិនបានធ្វើការចុះបញ្ជីទទួលសិទ្ធិបន្តឱ្យបានត្រឹមត្រូវ ។ តាមច្បាប់ លទ្ធកម្មបន្តពេលនេះ ដើមចោទជាអ្នកមានសិទ្ធិអត្ថិភាពនៃសិទ្ធិពេញលេញលើដីខាងលើនេះហើយ ។

**ខ- អំពីការទាមទារឱ្យចុះបញ្ជីផ្ទេរសិទ្ធិ ដីទំហំ ៤៧.៦០៦ម² មានក្បាលដីលេខ $I_{II}$ 0014**

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា ការទាមទារឱ្យចុងចម្លើយធ្វើការចុះបញ្ជីផ្ទេរដីខាងលើ មកឱ្យដើមចោទ ដោយហេតុថាពេលនេះដើមចោទត្រូវការធ្វើការចុះបញ្ជីដីដែលបានទិញឱ្យបានពេញលេញទៅតាមច្បាប់ និងតាមនីតិវិធី គឺតម្រូវឱ្យចុងចម្លើយឈ្មោះ [redacted] **កែវមុនី** មកបំពេញបែបបទទៅតាមនីតិវិធី តែពេលនេះ ចុងចម្លើយដែលជាម្ចាស់ដីដើម មិនដឹងថាទៅរស់នៅទីណានោះទេ ។ ពេលចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ផ្ទេរសិទ្ធិដីនេះមកឱ្យឈ្មោះ [redacted] **ជីតា** នោះ គឺមិនបានបំពេញកាតព្វកិច្ចឱ្យបានចប់សព្វគ្រប់តាមនីតិវិធី ។ ហេតុនេះ ពេលនេះ ចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ត្រូវមានកាតព្វកិច្ចក្នុងការមកបំពេញកាតព្វកិច្ចចុះបញ្ជីផ្ទេរសិទ្ធិដីនេះមកឱ្យដើមចោទ ដើម្បីឱ្យដើមចោទមានសិទ្ធិពេញ



Scanned with CamScanner

លេញក្នុងការទទួលបានសិទ្ធិជាម្ចាស់កម្មសិទ្ធិបន្ត ។

ស្នើសុំឱ្យតុលាការពិនិត្យភស្តុតាងដូចខាងក្រោម ៖

1- ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.I 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

2- ប្លង់ទីតាំងបែងចែកដីថ្មី ចេញដោយឃុំខ្មារសណ្ដាយ (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

3- សេចក្ដីចម្លងសំបុត្រមរណភាព ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] **គីវឡុន:**

4- លិខិតរបស់ឈ្មោះ [redacted] **កែវមុនី** និងកូនឈ្មោះ [redacted] **វឡុនាសត្យា** ឈ្មោះ [redacted] **វឡុនរមនា**, ឈ្មោះ [redacted] **វឡុវិច្ឆិកា** និងឈ្មោះ [redacted] **វឡុទិត្យបូរមី** (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

5- លិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ (ច្បាប់ថតចម្លង)ចំនួន ១ច្បាប់

6- កិច្ចសន្យា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ រវាងឈ្មោះ [redacted] **កែវមុនី** និងឈ្មោះ [redacted] **ជីតា** (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

7- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 050837128 ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **សុជឿន** (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

8- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010246891(01) ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៤ របស់ឈ្មោះ [redacted] **ជីតា** (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

9- សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតលេខ ២៣០៤ កពមក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted] **ជីតា** ចេញដោយរដ្ឋបាលខណ្ឌដូនពេញ (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់

10- កិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ រវាងឈ្មោះ [redacted] **ជីតា** និងឈ្មោះ [redacted] **សុជឿន** (ច្បាប់ថតចម្លង) ចំនួន ០១ច្បាប់ ។

### ៣-២ ការអះអាងរបស់ភាគីចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ត្រូវបានតុលាការកោះហៅឱ្យចូលរួមក្នុងកាលបរិច្ឆេទនៃនីតិវិធីរបស់តុលាការ ត្រឹមត្រូវតាមនីតិវិធីរួចហើយ ហើយក្រឡាបញ្ជីបានធ្វើការបញ្ជូនដីកាកោះ រួមនឹងពាក្យបណ្ដឹងនិងសេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទទៅឱ្យចុងចម្លើយរួចរាល់ហើយ ហើយតាមរបាយការណ៍ស្ដីពីការបញ្ជូន ក៏បានបង្ហាញឱ្យឃើញផងដែរថាឈ្មោះ [redacted] **សំណាង** ទូរស័ព្ទលេខ ០៩២ ១៧៩៩៩៩ បានទទួលទុកជំនួស ។ ចុងចម្លើយឈ្មោះ [redacted] **កែវមុនី** នៅតែអវត្តមាន និងមិនបានចូលរួមដដែល ដោយអត់មានមូលហេតុ ។

### ៣-៣ ការទាញហេតុផលចុងក្រោយ

មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ លោក [redacted] បានធ្វើការទាញហេតុផលចុងក្រោយថា ខ្លួននៅតែរក្សាការទាមទារ អង្គហេតុចាំបាច់បញ្ជាក់ការទាមទារ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងរបស់ខ្លួនដដែល និងស្នើសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចការទាមទារទាំងអស់របស់ខ្លួន ។



Scanned with CamScanner

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការសាកសួរ និងការពិនិត្យភស្តុតាងនានាក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា ៖

១- ពាក្យបណ្តឹងអង្គសេចក្តី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] **សុជឿន** ជាដើមចោទធ្វើឡើងត្រឹមត្រូវតាមច្បាប់ តុលាការអាចទទួលមកវិនិច្ឆ័យ និងសម្រេចសេចក្តីបាន ស្របតាមបញ្ញត្តិមាត្រា ៧ មាត្រា ៨ និងមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**២- អំពីការទាមទារឱ្យបញ្ជាក់អត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ ៤៧.៦០៦ ម²**

២-១ ភាគីដើមចោទបានអះអាងថាខ្លួនទាមទារឱ្យបញ្ជាក់ថាខ្លួនជាអ្នកមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **I_II 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដោយហេតុថា ដីនេះ គឺចុងចម្លើយនិងឈ្មោះ [redacted] **ជីតា** បានលក់និងផ្ទេរ សិទ្ធិមកឱ្យឈ្មោះ [redacted] **ជីតា** ដោយស្របច្បាប់ ហើយឈ្មោះ [redacted] **ជីតា** បានលក់បន្តមកឱ្យខ្លួន ដោយបានធ្វើតែលិខិតផ្ទេរសិទ្ធិកាន់កាប់ដី កិច្ចសន្យា និងកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី)តែប៉ុណ្ណោះ ពោលគឺគ្រាន់តែមិនទាន់បានចុះបញ្ជីទៅតាមនីតិវិធីតែប៉ុណ្ណោះ ។ ហេតុនេះ តាមច្បាប់ លទ្ធកម្មបន្តនេះ គឺខ្លួនជាអ្នកមានសិទ្ធិអត្ថិភាពនៃកម្មសិទ្ធិពេញលេញលើដីខាងលើនេះហើយ ។

២-២ ការអះអាងអំពីការទទួលបានសិទ្ធិបន្តលើដីខាងលើនេះ របស់ដើមចោទ មានភាពសមស្របនឹងលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧, កិច្ចសន្យា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ និងកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ព្រមទាំងភស្តុតាងទាំងឡាយក្នុងសំណុំរឿង ដែលឯកសារជាភស្តុតាងទាំងនេះ បានបង្ហាញឱ្យឃើញពីការផ្ទេរសិទ្ធិលើដីខាងលើនេះ ពីចុងចម្លើយឈ្មោះ [redacted] **កែវមុនី** មកឱ្យឈ្មោះ [redacted] **ជីតា** និងផ្ទេរបន្តពីឈ្មោះ [redacted] **ជីតា** មកឱ្យដើមចោទឈ្មោះ [redacted] **សុជឿន** ។ ផ្ទុយទៅវិញ តាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ បានបង្ហាញថាឈ្មោះ [redacted] **កែវមុនី** ជាចុងចម្លើយ នៅតែជាម្ចាស់កម្មសិទ្ធិលើដីនេះដដែល ។

២-៣ ការដែលដើមចោទបានលើកយកលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧, កិច្ចសន្យា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ និងកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៣ ព្រមទាំងភស្តុតាងជាឯកសារទាំងឡាយក្នុងសំណុំរឿង មកធ្វើការអះអាងអំពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិរបស់ខ្លួន លើដីខាងលើនេះ ***តុលាការពិនិត្យនិងយល់ឃើញថា*** ឯកសារជាភស្តុតាងទាំងអស់នេះ មិនអាចបញ្ជាក់ជាផ្លូវការនិងស្ថាពរនូវអត្ថិភាពនៃសិទ្ធិជាម្ចាស់កម្មសិទ្ធិរបស់ដើមចោទលើដីដែលជាអចលនវត្ថុ ស្របតាមមូលដ្ឋានគោលការណ៍សិទ្ធិកម្មសិទ្ធិ ដែលជាសិទ្ធិប្រត្យក្សលើអចលនវត្ថុ តាមមូលដ្ឋានគតិយុត្តជាធរមាននោះទេ ដោយហេតុថា ដើមចោទមិនទាន់ទទួលបាននូវការចុះបញ្ជីកម្មសិទ្ធិលើដីនេះ នៅឡើយទេ ។ ហេតុនេះ តុលាការយល់ឃើញថាការទាមទាររបស់ដើមចោទ ឱ្យតុលាការសម្រេចបញ្ជាក់ថាដើមចោទជាអ្នកមានអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **I_II 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិត នៅ



Scanned with CamScanner

ភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប មិនមានភាពត្រឹមត្រូវនោះទេ ដែលតុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចប្រានចោលនូវការទាមទារនេះ ។

**៣- អំពីការទាមទារឱ្យធ្វើនីតិវិធីចុះបញ្ជីផ្ទេរសិទ្ធិលើដីទំហំ ៤៧.៦០៦ម$^2$ ក្បាលដីលេខ I$_{II}$ 0014**

៣-១ ភាគីដើមចោទបានអះអាងថា ខ្លួនទាមទារឱ្យចុងចម្លើយធ្វើការចុះបញ្ជីផ្ទេរដីខាងលើមកឱ្យខ្លួន ដោយហេតុថាពេលនេះ ខ្លួនត្រូវការធ្វើការចុះបញ្ជីដីដែលបានទិញឱ្យបានពេញលេញទៅតាមច្បាប់ និងតាមនីតិវិធី គឺតម្រូវឱ្យចុងចម្លើយឈ្មោះ [redacted] **កែវមុនី** មកបំពេញបែបបទទៅតាមនីតិវិធី តែពេលនេះ ចុងចម្លើយដែលជាម្ចាស់ដីដើម មិនដឹងថាទៅរស់នៅទីណានោះទេ ។ ពេលចុងចម្លើយផ្ទេរសិទ្ធិដីមកឱ្យឈ្មោះ [redacted] **ជីតា** នោះ គឺមិនបានបំពេញកាតព្វកិច្ចឱ្យបានចប់សព្វគ្រប់តាមនីតិវិធី ។ ហេតុនេះ ពេលនេះ ចុងចម្លើយត្រូវមានកាតព្វកិច្ចក្នុងការមកបំពេញកាតព្វកិច្ចចុះបញ្ជីផ្ទេរសិទ្ធិដីនេះមកឱ្យខ្លួន ដើម្បីឱ្យខ្លួនមានសិទ្ធិពេញលេញក្នុងការទទួលបានសិទ្ធិជាម្ចាស់កម្មសិទ្ធិបន្ត ។

៣-២ *ឃើញថា* ការអះអាងនូវការទាមទាររបស់ដើមចោទ ក្នុងការទទួលបាននូវសិទ្ធិបន្តលើដីដែលជាកម្មវត្ថុនេះ មានភាពសមស្របនឹងលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០០៧, កិច្ចសន្យា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ និងកិច្ចសន្យាលក់-ទិញអចលនវត្ថុ(ដីធ្លី) ចុះថ្ងៃទី ០៤ ខែមករា ឆ្នាំ២០២៣ ព្រមទាំងភស្តុតាងទាំងឡាយក្នុងសំណុំរឿង ដែលឯកសារទាំងនេះបានបង្ហាញឱ្យឃើញពីការផ្ទេរសិទ្ធិលើដីខាងលើនេះ ពីចុងចម្លើយឈ្មោះ [redacted] **កែវមុនី** មកឱ្យឈ្មោះ [redacted] **ជីតា** និងផ្ទេរបន្តពីឈ្មោះ [redacted] **ជីតា** មកឱ្យដើមចោទឈ្មោះ [redacted] **សុជឿន** ។ ផ្ទុយទៅវិញ តាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ បានបង្ហាញថាឈ្មោះ [redacted] **កែវមុនី** នៅតែជាម្ចាស់កម្មសិទ្ធិលើដីនេះដដែល ។ ត្រង់នេះ តុលាការពិនិត្យឃើញថាឈ្មោះ [redacted] **ជីតា** ដែលជាអ្នកទទួលសិទ្ធិដំបូងពីចុងចម្លើយឈ្មោះ [redacted] **កែវមុនី** មិនបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] **កែវមុនី** ប្រគល់ដីនិងចុះបញ្ជីផ្ទេរសិទ្ធិលើដីនេះ មកឱ្យខ្លួននោះទេ ប៉ុន្តែខ្លួនបានផ្ទេរសិទ្ធិបន្តមកឱ្យដើមចោទឈ្មោះ [redacted] **សុជឿន** ។ ករណីនេះ តុលាការយល់ឃើញថា ការដែលដើមចោទឈ្មោះ [redacted] **សុជឿន** ឡើងមកអនុវត្តសិទ្ធិទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] **កែវមុនី** អនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា គឺជាការអនុវត្តសិទ្ធិត្រឹមត្រូវតាមច្បាប់ ដោយហេតុថាក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ នៅតែមានឈ្មោះចុងចម្លើយ [redacted] **កែវមុនី** ជាម្ចាស់កម្មសិទ្ធិ ហើយភស្តុតាងជាឯកសារផ្ទេរសិទ្ធិលើដីខាងលើនេះ ក៏បានបង្ហាញអំពីឆន្ទៈរបស់គូភាគីក្នុងការលក់ទិញដីនេះ ដែលស្របតាមគោលការណ៍ស្វ័យភាពនៃឆន្ទៈហើយដែរ ។ ហេតុនេះ តុលាការយល់ឃើញថា ការទាមទាររបស់ភាគីដើមចោទត្រង់ចំណុចនេះ មានហេតុផលសមរម្យ ដែលតុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចទទួលស្គាល់ការទាមទារនេះ ។

**៤- អំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

ភាគីដើមចោទបានអះអាងថាខ្លួនយល់ព្រមទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។ ហេតុនេះ តុលាការគប្បីសម្រេចឱ្យភាគីដើមចោទនេះ ទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ស្របតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ចុងចម្លើយឈ្មោះ [redacted] កែវមុនី ត្រូវបានតុលាការកោះហៅ ត្រឹមត្រូវតាមនីតិវិធីរួចហើយ ហើយការបញ្ជូនក៏បានអនុវត្តត្រឹមត្រូវតាមនីតិវិធីហើយដែរ ប៉ុន្តែភាគីចុងចម្លើយនៅតែអវត្តមាន ដោយគ្មានមូលហេតុ ។ ហេតុនេះ តុលាការចាត់ទុកថាចុងចម្លើយដែលអវត្តមានបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ស្របតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១- ប្រានចោលការទាមទារឱ្យបញ្ជាក់ថា ដើមចោទជាម្ចាស់មានអត្តិភាពនៃសិទ្ធិលើកម្មសិទ្ធិ ដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **I$_{II}$ 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស. រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

២- បង្គាប់ឱ្យចុងចម្លើយ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរសិទ្ធិលើដីទំហំ **៤៧.៦០៦ម²** មានក្បាលដីលេខ **I$_{II}$ 0014** មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ស.រ 003276** ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៨ មានទីតាំងស្ថិតនៅភូមិសណ្តាយ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប មកឱ្យដើមចោទ ។

៣- ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ភាគីអាចប្តឹងឧបាស្រ័យ តាមមាត្រា ២០៤ មាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ក្រឡាបញ្ជី**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រម**
ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តសៀមរាប ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ចៅក្រម**

[redacted]



Scanned with CamScanner